**សេចក្ដីប្រកាសព័ត៌មានរបស់ ម.ស.ម.ក**

# បច្ចុប្បន្នភាព៖ យុវជនទីពីរត្រូវបានចោទប្រកាន់និងបញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្ន ពាក់ព័ន្ធនឹងទិវាប្រារព្ធខួប៣ឆ្នាំនៃឃាតកម្មលើលោកបណ្ឌិត កែម ឡី

ភ្នំពេញថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩

*ប្រភេទនៃការរំលោភបំពាន ៖ រំលោភលើសេរីភាពមូលដ្ឋាន*

*សិទ្ធិពាក់ព័ន្ធ ៖ សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី*

នៅព្រឹកថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៩ លោក សួង នាគព័ន្ធ ត្រូវបានចៅក្រមស៊ើបអង្កេតនៅសាលាដំបូងរាជធានីភ្នំពេញបន្តការសាកសួរ។ មួយម៉ោងបន្ទាប់ពីការសាកសួរនោះ គាត់ត្រូវបានចោទប្រកាន់ជាផ្លូវការពី "បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ" ក្រោមមាត្រា៤៩៤ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្ន។

សូមមើលព័ត៌មានលំអិតនៃការរឹតត្បិតលើសេរីភាពមូលដ្ឋានដែលបានកើតឡើងក្នុងអំឡុងពេលរំលឹកខួប៣ឆ្នាំនៃឃាតកម្មលើលោកបណ្ឌិតកែម ឡី តាមរយៈសេចក្ដីប្រកាសព័ត៌មានរបស់ម.ស.ម.ក ដែលបានចេញផ្សាយកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ ស្ដីពី «**ការរឹតត្បិតទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិនិងសេរីភាពខាងការជួបប្រជុំដោយសន្តិវិធីរួមទាំងការចាប់ខ្លួនសកម្មជនយុវជនក្នុងទិវាប្រារព្ធខួប៣ឆ្នាំនៃឃាតកម្មលើលោកបណ្ឌិត កែម ឡី**» ដូចមានក្នុងតំណ៖ http://bit.ly/2S5GGSw.

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សួន យុធ្យា នាយកតស៊ូមតិ នៃ ម.ស.ម.ក តាមរយៈទូរស័ព្ទ៖ +៨៥៥ (0) ៨៨ ៨១ ៤២ ៧៨៣ ឬអ៊ីម៉ែល ៖ yuthyia@cchrcambodia.org។**

--- ចប់---